**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * * * * * * * * * *

# កិច្ចព្រមព្រៀង

**រវាង**

**ក្រុមហ៊ុន អិមធីយេស៍ហ្គាមេន ខេមបូឌា ខូអិលធីឌី**

**ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន**

នៅថ្ងៃទី០២ ខែ មករា ឆ្នាំ២០២៣ វេលាម៉ោង ០១ រសៀល នៅក្នុងរោងចក្រ អិមធីយេស៍ហ្គាមេន មានកិច្ចប្រជុំជាមួយតំណាងក្រុមហ៊ុន និងសហជីព តំណាងកម្មករ និយោជិក។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិកទាំងអស់ស្ដីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលឲ្យសង្វាក់ផលិតកម្មត្រូវផ្អាកកម្មករមួយចំនួន។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ៥៧ នាក់ (ស្រី ៣៨ នាក់)

រយៈពេល ៣០ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០២ ខែ មករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែ មករា ឆ្នាំ២០២៣។ ហើយកំឡុងពេលព្យួរការងារនេះ កម្មករនិយោជិកបានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឧបត្ថម្ភក្នុងមួយខែ ៣០ ដុល្លារសហរដ្ឋអាមេរិច។

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនិងបើកជូនបងប្អូនកម្មករនៅថ្ងៃមុនថ្ងៃព្យួរកិច្ចសន្យានេះ។ អង្គប្រជុំនេះបានបញ្ចប់នៅវេលាម៉ោង ២:០០ នាទីរសៀល នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃទី០២ ខែមាឃ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

ភ្នំពេញ, ថ្ងៃទី០២ ខែ មករា ឆ្នាំ២០២៣

**តំណាងកម្មករ និងតំណាងសហជីព**

**នាយកក្រុមហ៊ុន**

ក្រុមហ៊ុន អិម ធី យេស៍ ហ្គាមេន (ខេមបូឌា)
MT. YEH'S GARMENT (CAMBODIA) CO.,LTD
KINGDOM OF CAMBODIA

Scanned with CamScanner